រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ព្រឹត្តិបត្រ

លេខ ១៥ ខែមីនា ឆ្នាំ២០១០

# មេរៀនទទួលបានពីរយៈពេល ១០ ឆ្នាំ នៃការផលិតសម្លៀកបំពាក់ប្រកបដោយការទទួលខុសត្រូវ




*ឯកឧត្តម ចម ប្រសិទ្ធ និងអ្នកតំណាងដទៃទៀតថ្លែងនៅឯសន្និសីទ*

អង្គការពលកម្មអន្តរជាតិ (ILO) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានរៀបចំសន្និសីទកម្រិតខ្ពស់មួយស្តីពី ការច្បាមយកការលើកទឹកចិត្តជាសកលសម្រាប់ការអភិវឌ្ឍន៍ក្នុងទីក្រុងវ៉ាស៊ីងតោន កាលពីថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

សន្និសីទនេះមានការចូលរួមពីអ្នកដែលមានការពាក់ព័ន្ធជាច្រើន ដូចជា អ្នកបញ្ជាទិញអន្តរជាតិ មន្ត្រីរដ្ឋាភិបាលសហរដ្ឋអាមេរិក សមាគមនិយោជកនិងសហជីពអន្តរជាតិ សមាគមនិយោជក និងសហជីពអាមេរិក ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកដឹកនាំគោលនយោបាយ អ្នកផ្តល់ជំនួយនិងទីភ្នាក់ងារបច្ចេកទេស ក្រុមអ្នកជំនាញ និងសហគមន៍ស្រាវជ្រាវគោលនយោបាយ និងតំណាងជាន់ខ្ពស់របស់ធនាគារពិភពលោក និងរបស់ IFC។

សន្និសីទនេះ ដែលរៀបចំឡើងក្នុងឱកាសខួបលើកទី ១០ នៃកិច្ចព្រមព្រៀងវាយនភ័ណ្ឌទ្វេភាគីរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជា ដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ ១៩៩៩ គឺជាឱកាសមួយ ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីបទពិសោធន៍ជាក់ស្តែង ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ និងសមត្ថភាពប្រកួតប្រជែងនៅក្នុងសង្វាក់នៃការផ្គត់ផ្គង់ជាសកល។ បទពិសោធន៍របស់ប្រទេសកម្ពុជាត្រូវបានលើកយកមកពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងកិច្ចប្រជុំសំខាន់មួយដែលមានឈ្មោះថា មេរៀនទទួលបានពីរយៈពេល ១០ ឆ្នាំ នៃការផលិតសម្លៀកបំពាក់ប្រកបដោយការទទួលខុសត្រូវ។ អ្នកមានតួនាទីសំខាន់ៗនៅក្នុងឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា ត្រូវបានអញ្ជើញឱ្យឡើងឆ្លុះបញ្ចាំងអំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងអំពីកម្មវិធី*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៃអង្គការពលកម្មអន្តរជាតិ និងឡើងថ្លែងអំពីបទពិសោធន៍របស់ពួកគេពាក់ព័ន្ធជាមួយនឹងគោលនយោបាយថ្មីនេះ។ ឯកឧត្តម បណ្ឌិត Ghazi Shbeikat រដ្ឋមន្ត្រីក្រសួងការងារមកពីប្រទេសហ្សកដង់ ក៏បានចូលរួមនៅក្នុងកិច្ចប្រជុំនេះក្នុងនាមជាវាគ្មិនមួយរូបផងដែរ។

### មានការសម្រេចបាននូវវឌ្ឍនភាពពិតប្រាកដ ប៉ុន្តែនៅតែមានចំណុចដែលត្រូវកែលំអ

លោក ទ័រម៉ូ ប៉ូទីអែណិន ប្រធានទីប្រឹក្សាបច្ចេកទេសរបស់គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានធ្វើបទឧទ្ទេសនាមអំពីកម្មវិធី និងបង្ហាញពីទិដ្ឋភាពរួមនៃប្រវត្តិ និងការវិវឌ្ឍន៍របស់កម្មវិធីនេះ។

លោកបានគូសបញ្ជាក់ថា ផ្អែកតាមទិន្នន័យដែលប្រមូលដោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ចាប់តាំងពីឆ្នាំ ២០០១ មក គេអាចកត់សម្គាល់ឃើញមានការកែលំអជាច្រើនផ្នែកលក្ខខណ្ឌការងារជារួម។ តែទោះជាយ៉ាងណាក៏ដោយ នៅមានផ្នែកមួយចំនួន ដែលចាំបាច់ត្រូវកែលំអបន្ថែម (ជាពិសេស ពាក់ព័ន្ធជាមួយនឹងសេរីភាពនៃការបង្កើតអង្គការវិជ្ជាជីវៈ ការរើសអើង និងសុខភាពនិងសុវត្ថិភាពការងារជាដើម) ប៉ុន្តែការអនុលោមទៅតាមច្បាប់ការងារថ្នាក់ជាតិពាក់ព័ន្ធនឹងការបើកប្រាក់ឈ្នួល និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗមានកម្រិតខ្ពស់ដូចៗគ្នា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់សមាជិកឧស្សាហកម្មក៏មានការរីកចម្រើនផងដែរនៅក្នុងផ្នែកទំនាក់ទំនងវិជ្ជាជីវៈក្នុងវិស័យកាត់ដេរ ដែលអាចឆ្លុះបញ្ចាំងបានតាមរយៈការកើនឡើងនៃចំនួនអនុសញ្ញារួម និងការកាត់បន្ថយចំនួនកូដកម្មដែលកើតមានឡើង។

### ការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មជាមួយពលកម្មក្នុងវិស័យកាត់ដេរ គឺជាផ្នែកមួយនៃទស្សនៈវិស័យរយៈពេលវែងរបស់រដ្ឋាភិបាល ដើម្បីសម្រេចនូវការអភិវឌ្ឍន៍ដែលផ្តល់ការគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រ

នៅក្នុងសន្និសីទនេះដែរ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានឡើងថ្លែងអំពីប្រវត្តិដើមនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងគោលនយោបាយភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មជាមួយពលកម្ម។ ឯកឧត្តមបានរំឭកអ្នកចូលរួមក្នុងសន្និសីទនេះថា ប្រទេសកម្ពុជាបានងើបចេញពីសង្គ្រាម និងអស្ថិរភាពក្នុងរយៈពេលដ៏សែនលំបាក ហើយបានចាប់ផ្តើមពីបាតដៃទទេសុទ្ធសាធ។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានផ្តល់លទ្ធភាពឱ្យឧស្សាហកម្មកាត់ដេរ មានការរីកចម្រើនយ៉ាងឆាប់រហ័ស និងបានបន្តចូលរួមចំណែកបង្កើនសមត្ថភាពប្រកួតប្រជែងរបស់ឧស្សាហកម្មនេះនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។

ប៉ុន្តែ ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ថា បើទោះបីជាគោលនយោបាយនេះបានជួយប្រទេសកម្ពុជាឱ្យអាចកសាងកេរ្តិ៍ឈ្មោះជាប្រភពផលិតកម្មប្រកបដោយការទទួលខុសត្រូវ និងបើទោះបីជាការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានចូលរួមចំណែកធ្វើឱ្យឧស្សាហកម្មនេះនៅឋិតថេរ បន្ទាប់ពីមានការលុបចោលប្រព័ន្ធកូតាក៏ដោយក៏លក្ខខណ្ឌទាំងនេះនៅមិនទាន់គ្រប់គ្រាន់ ដើម្បីធានាឱ្យឧស្សាហកម្មនេះមាននិរន្តរភាពរយៈពេលវែងឡើយ។ ឯកឧត្តមបានលើកឡើងថា ឧស្សាហកម្មនេះចាំបាច់ត្រូវបន្តកែលំអការងាររបស់ខ្លួនទៀត ដើម្បីអាចបន្តទាក់ទាញអ្នកបញ្ជាទិញ និងអាចប្រកួតប្រជែងជាមួយប្រទេសដែលមានចំណូលទាបដទៃទៀតបាន។

### សមត្ថភាពប្រកួតប្រជែងជារួមតម្រូវឱ្យមានការវិនិយោគបន្ថែមទៀតលើផលិតភាព និងធនធានមនុស្ស

ក្នុងនាមតំណាងឱ្យនិយោជក លោក វ៉ាន់ ស៊ូអៀង ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានលើកឡើងអំពីគោលនយោបាយរបស់រដ្ឋាភិបាល និងពេលដែលគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*

*សូមអានតទៅទំព័រទី ២*

# បង្កើនប្រសិទ្ធិភាពនៃឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា៖ ផ្លូវបៃតងនៅខាងមុខ

ការធ្វើឱ្យប្រសើរនូវការបំពេញការងារ គឺជាការងារសំខាន់ដែលគ្រប់ម្ចាស់ធុរកិច្ចទាំងអស់ត្រូវធ្វើជាបន្តបន្ទាប់។ ករណីនេះគឺកាន់តែពិសេសក្នុងពេលមានវិបត្តិកើតឡើង។ ការផ្តោតសំខាន់លើប្រសិទ្ធិភាពថាមពល នៅក្នុងរោងចក្រកាត់ដេរ និងការដាក់បញ្ចូលការគ្រប់គ្រងបរិស្ថានឱ្យកាន់តែទូលំទូលាយនៅក្នុងដំណើរការសំខាន់ៗរបស់ក្រុមហ៊ុនអាចជួយបង្កើនគុណភាពផលិតភាព និងបរិស្ថាន ក៏ដូចជាប្រសិទ្ធិភាព និងលទ្ធភាពចំណេញជារួម។ នេះនឹងផ្តល់នូវអត្ថប្រយោជន៍ដោយផ្ទាល់ដល់អ្នកគ្រប់គ្រង និងកម្មករនិយោជិតនៅក្នុងឧស្សាហកម្មកាត់ដេរ និងប្រទេសកម្ពុជាទាំងមូល។

ជាមួយនឹងការគាំទ្រពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជំហានទី ១ ត្រូវបានអនុវត្ត ដើម្បីផ្តល់នូវសេវាថ្មីៗសំដៅគាំទ្រឱ្យរោងចក្រកាត់ដេរកម្ពុជាអាចបោះជំហានសម្រេចបាននូវផលិតកម្ម ដែលមានប្រសិទ្ធិភាព និងបៃតងជាងមុន។ ភាពជាដៃគូនេះលើកកម្ពស់ការងារបៃតង[១] ដែលចូលរួមចំណែកចំពោះកំណើនរួមគ្នា ហើយក្នុងពេលតែមួយអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងធ្វើឱ្យកន្លែងធ្វើការមានពណ៌បៃតងតាមរយៈការលើកទឹកចិត្តឱ្យនិយោជក និងនិយោជិតបង្កើនប្រសិទ្ធិភាពថាមពលនៃទីកន្លែង និងបរិក្ខារដែលមានស្រាប់។ ភាពជាដៃគូនេះក៏ទាញប្រយោជន៍ពីបទពិសោធន៍របស់ IFC ផ្នែកផលិតកម្មស្អាត និងប្រសិទ្ធិភាពថាមពលផងដែរ។

ជាផ្នែកមួយនៃផែនការទូលំទូលាយ (ដែលរួមបញ្ចូលការបង្កើតឯកសារបណ្តុះបណ្តាលថ្មីៗ សម្រាប់បង្កើនការយល់ដឹងអំពីបរិស្ថាន គោលនយោបាយបៃតងគំរូ ឯកសារអំពីការអនុវត្តល្អៗ សេវាផ្តល់ប្រឹក្សា និងសេវាដទៃទៀត) ការអង្កេតបឋមសម្រាប់កំណត់ចំណុចដៅផ្នែកថាមពលលើរោងចក្រ ១២% (រោងចក្រចំនួន ៣១) ក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ត្រូវបានធ្វើឡើងកាលពីពេលថ្មីៗនេះ ដើម្បីដឹងពីទិដ្ឋភាពរួមឱ្យបានច្បាស់លាស់អំពីឥរិយាបថថាមពលរបស់ឧស្សាហកម្មនេះ។ លទ្ធផលនៃការអង្កេតនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅក្នុងសិក្ខាសាលាផ្សព្វផ្សាយមួយ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ។ ការអង្កេតនេះត្រូវបានធ្វើឡើងដោយក្រុមហ៊ុន BDLINK Cambodia និងអ្នកជំនាញផ្នែកថាមពលមកពីក្រុមហ៊ុនកូមីនខ្មែរ។

*សូមអានតទៅទំព័រទី ២*



*រូបភាពក្នុងរោងចក្រកាត់ដេរថតពីលើ*

[១] *សូមមើលគំនិតផ្តួចផ្តើមការងារបៃតងរបស់ ILO ក្នុង* *http://www.ilo.org/integration,themes/greenjobs/lang--en/index.htm*

## ផ្នែកខាងក្នុង

ខ្ញុំមានតំលៃឆ្នាំ ២០០៩ ឈានមកដល់ទីបញ្ចប់
និស្សិតមួយក្រុមស្វែងយល់ពីវិស័យកាត់ដេររបស់កម្ពុជា
ជ័យលាភីនៃការប្រកួតប្រជែង “ខ្ញុំមានតំលៃ” ឆ្នាំ ២០០៩

# ផ្លូវបៃតងនៅខាងមុខ...

*តមកពីទំព័រទី ១*

នេះគឺជាលើកដំបូងហើយ ដែលឧស្សាហកម្មនេះបានចាប់ផ្តើមបង្កើតចំណុចដៅផ្នែកថាមពល។ ការបង្កើតចំណុចដៅនេះផ្តល់លទ្ធភាពឱ្យអ្នកគ្រប់គ្រងធ្វើការវាយតម្លៃការអនុវត្តការងាររបស់ខ្លួន ដោយធ្វើការប្រៀបធៀបជាមួយនឹងធុរកិច្ចស្រដៀងគ្នាដែលមានប្រតិបត្តិការក្នុងបរិបទដូចគ្នានេះ។ បច្ចេកទេសនេះផ្តល់អ្នកគ្រប់គ្រងនូវឧបករណ៍ចាំបាច់ដើម្បីផ្តោតការយកចិត្តទុកដាក់លើការងារគេហកិច្ច ដែលអាចកាត់បន្ថយចំណាយដល់កម្រិតអប្បបរមា និងដើម្បីវាយតម្លៃលើជម្រើសបច្ចេកវិទ្យាថ្មីៗ។

ប្រភេទសម្លៀកបំពាក់ ទំហំផលិតកម្ម ចំនួននិយោជិត ទំហំរោងចក្រ អាយុកាលរបស់ម៉ាស៊ីន និងអាយុកាលរបស់រោងចក្រដែលចូលរួមនីមួយៗ ត្រូវបានយកមកធ្វើការពិចារណា ដើម្បីបង្កើតចំណាត់ថ្នាក់។ លទ្ធផលពិស្តារនៃការអង្កេតនេះមាននៅក្នុង www.betterfactories.org។

**តារាងខាងក្រោមនេះបង្ហាញពីចំណុចសំខាន់ៗមួយចំនួនរបស់ការអង្កេតនេះ។**

| សូចនាករ | លទ្ធផល |
| --- | --- |
| កម្រិតប្រើប្រាស់ថាមពល | • កម្រិតប្រើប្រាស់ថាមពលគិតជាមធ្យមរបស់រោងចក្រទាំងអស់គឺ ៤២GJ[១] ក្នុងមួយតោននៃសម្លៀកបំពាក់ដែលបានផលិត ដោយមានកម្រិតចាប់ពីប្រហែល ២GJ ទៅ ២៣៧GJ ក្នុងផលិតផលមួយតោន ដោយរោងចក្រចំនួន ៥០% មានកម្រិតប្រើប្រាស់ថាមពលក្រោម ២៥,២J ក្នុងមួយតោន។<br>• អគ្គិសនីគឺជាផ្នែកតូចមួយនៃកម្រិតប្រើប្រាស់ថាមពលសរុប ដោយថាមពលភាគច្រើនប្រើប្រាស់ឥន្ធនៈដទៃទៀត។<br>• រោងចក្រដែលផលិតកម្មមានកម្រិតប្រើប្រាស់ថាមពលច្រើនជាងគេក្នុងផលិតផលមួយតោន គឺជារោងចក្រដែលផលិតសម្លៀកបំពាក់ផ្នែកខាងក្រោម (៥៦GJ ក្នុងផលិតផលមួយតោន) និងអាវ (៥៥GJ ក្នុងមួយតោន) និងរោងចក្រដែលមាននិយោជិតចាប់ពី ៣០០០ នាក់ឡើងទៅ (៧៤GJ ក្នុងមួយតោន)។<br>• ម៉ាស៊ីន ដែលមានអាយុកាលតិចជាង ៣ ឆ្នាំប្រើប្រាស់ថាមពលតិចតួចជាងគេ (២៥,៦GJ ក្នុងមួយតោន) ក្នុងផលិតផលមួយតោន (១០,៣GJ/t) ក្នុងនិយោជិតម្នាក់ និងក្នុងមួយផ្នែកផលិតកម្ម (១,៧GJ/t)។ |
| ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) | • ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការប្រើប្រាស់អគ្គិសនីមានចំនួន ៦០% បន្ទាប់ពីការប្រើប្រាស់ប្រេងម៉ាសូត (២៤%)។<br>• មានទំនាក់ទំនងទៅវិញទៅមករវាងទិន្នផលផលិតកម្ម និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។<br>• ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ខ្ពស់បំផុតឃើញមាននៅក្នុងរោងចក្រ ដែលមានកម្រិតប្រើប្រាស់ថាមពលទាប។ |
| ការប្រើប្រាស់ និងការចំណាយលើថាមពល | • ការចំណាយលើថាមពលគិតជាមធ្យម ដើម្បីផលិតសម្លៀកបំពាក់មួយតោន គឺ ៥៦០ ដុល្លា។ មានភាពខុសប្លែកគ្នាឆ្ងាយរវាងរោងចក្រមួយ និងរោងចក្រមួយទៀត ដោយការចំណាយមានតម្លៃចាប់ពី ៣០ ដុល្លាដល់ ១៧៣៧ ដុល្លា ក្នុងសម្លៀកបំពាក់មួយតោនដែលបានផលិត។<br>• ការចំណាយលើថាមពលមានអត្រា ១៦,៧% នៃថ្លៃដើមផលិតកម្មសរុប។ មានភាពខុសប្លែកគ្នាឆ្ងាយរវាងរោងចក្រមួយ និងរោងចក្រមួយទៀត ចាប់ពីកម្រិតទាបត្រឹម ៦% រហូតខ្ពស់ដល់ ៦០%។ រោងចក្រឆ្លើយតបចំនួន ៣១% បានចំណាយលើថាមពលគិតជាភាគរយខ្ពស់ជាងកម្រិតមធ្យម។<br>• រោងចក្រទាំងអស់សុទ្ធតែប្រើអគ្គិសនី។ ប៉ុន្តែ អគ្គិសនីមានកម្រិតត្រឹមតែ ២៤,៥% នៃការប្រើប្រាស់ថាមពលសរុបតែប៉ុណ្ណោះ ហើយការចំណាយលើអគ្គិសនីមានអត្រា ៥៣% នៃការចំណាយលើថាមពលសរុបក្នុងផលិតផលមួយតោន។<br>• អុសត្រូវបានប្រើប្រាស់ ដើម្បីផលិតថាមពលចំនួន ៤៣,៣% នៃថាមពលសរុប ដែលប្រើប្រាស់ក្នុងរោងចក្រ និងត្រូវបានប្រើប្រាស់ដោយរោងចក្រភាគច្រើន (៧១%)។ អុសគឺជាប្រភពថាមពល ដែលមានតម្លៃថោកជាងគេ និងមានអត្រាត្រឹមតែ ១០% ប៉ុណ្ណោះ នៃចំណាយលើថាមពលសរុបក្នុងផលិតផលមួយតោន។ |
| ការប្រើប្រាស់អគ្គិសនី | • ម៉ាស៊ីនដេរ និងម៉ាស៊ីនផ្សេងទៀតដែលប្រើក្នុងផលិតកម្ម (៣៨,៩%) និងភ្លើងបំភ្លឺ (២៣,៩%) ប្រើប្រាស់អគ្គិសនីច្រើនជាងគេនៅក្នុងប្រតិបត្តិការរបស់រោងចក្រ។ ក្នុងចំណោមការប្រើប្រាស់អគ្គិសនីសរុបសម្រាប់ភ្លើងបំភ្លឺផ្នែកផលិតកម្មប្រើប្រាស់ត្រឹមតែ ២២% ប៉ុណ្ណោះ។<br>• រោងចក្រថ្មីៗប្រើប្រាស់ថាមពលសម្រាប់បំភ្លឺនៅក្នុងផ្នែកផលិតកម្មរបស់ខ្លួន (៥៥ គីឡូវ៉ាត់ម៉ោងក្នុងមួយតោន) ច្រើនជាងរោងចក្រដែលបង្កើតយូរមកហើយ (២៦ គីឡូវ៉ាត់ម៉ោងក្នុងមួយតោន)។<br>• ការប្រើប្រាស់ថាមពលសម្រាប់បំភ្លឺផ្នែកផលិតកម្មមានការថយចុះ នៅពេលមានទិន្នផលផលិតកម្មខ្ពស់ជាងមុន និងទំហំផ្នែកផលិតកម្មធំជាងមុន។ |

រោងចក្រអាចចាត់វិធានការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលសរុបរបស់ខ្លួន។ ការស្រាវជ្រាវបានបង្ហាញថា ផ្នែកសំខាន់ៗដែលត្រូវយកចិត្តទុកដាក់រួមមាន ប្រព័ន្ធបំភ្លឺ ឧបករណ៍គ្រប់គ្រងម៉ាស៊ីនដេរ ប្រព័ន្ធធ្វើឱ្យមានខ្យល់ចេញចូល និងប្រព័ន្ធចំហាយទឹក។ មិនមែនគ្រប់វិធានការដើម្បីសន្សំសំចៃថាមពលទាំងអស់សុទ្ធតែត្រូវការវិនិយោគច្រើននោះទេ។ តាមពិតទៅជារឿយៗ ការផ្លាស់ប្តូរចាំបាច់ជាច្រើនអាចធ្វើឡើងដោយមិនមានការចំណាយ ឬចំណាយតិចតួច។

បច្ចុប្បន្ននេះ គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* និង IFC កំពុងធ្វើសវនកម្មលំអិតលើការប្រើប្រាស់ ថាមពលនៅក្នុងរោងចក្រ ដែលនឹងធ្វើការកំណត់ពីវិធានការកាន់តែច្បាស់លាស់បន្ថែមទៀត ដែលឧស្សាហកម្មនេះអាចបង្កើតឡើង ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធិភាព ហើយក្នុងពេលជាមួយគ្នា អាចការពារបរិស្ថាន និងកែលំអការគ្រប់គ្រងជារួមនៅក្នុងរោងចក្រ។

សេចក្តីណែនាំអំពីការអនុវត្តឱ្យបានល្អនឹងមានក្នុងពេលឆាប់ៗនេះ ហើយនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងឧស្សាហកម្មនេះទាំងមូល។ ឧបករណ៍ដទៃទៀតសម្រាប់ឧស្សាហកម្មនេះកំពុងត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូជាមួយកម្មវិធីការងារកាន់តែប្រសើរជាសកល ដែលនេះជាវិធីមួយសម្រាប់ផ្តល់ការគាំទ្រដល់ឧស្សាហកម្មកាត់ដេរនៅកម្ពុជានៅលើគន្លងផ្លូវដើម្បីក្លាយទៅជាទិសដៅផលិតសម្លៀកបំពាក់ប្រកបដោយគុណធម៌ និងការយកចិត្តទុកដាក់ចំពោះបរិស្ថាន។

*[១] ជីកាចូល (GJ) គឺជារង្វាស់ ដែលប្រើប្រាស់សម្រាប់វាស់វែងការប្រើប្រាស់ថាមពល។ ១GJ ស្មើនឹង ២៧៧,៨ គីឡូវ៉ាត់ក្នុងមួយម៉ោងនៃអគ្គិសនី ឬ ២៥,៨ លីត្ររបស់ប្រេងកម្តៅ។*

# មេរៀនទទួលបានពីរយៈពេល ១០ ឆ្នាំ...

*តមកពីទំព័រទី ១*

ទើបចាប់ផ្តើមដំបូង និងពីរបៀបដែលកត្តាទាំង ២ នេះ បានពាំនាំមកនូវអត្ថប្រយោជន៍ដ៏អស្ចារ្យ និងបានជួយបង្កើតឧស្សាហកម្មពិតប្រាកដជាលើកដំបូងមួយនៅក្នុងប្រទេសនេះ។ លោកបានរំឭកអ្នកចូលរួមនៅក្នុងសន្និសីទនេះថា ការកែលំអលក្ខខណ្ឌការងារតែមួយមុខមិនទាន់គ្រប់គ្រាន់សម្រាប់សមត្ថភាពប្រកួតប្រជែងជារួមបានឡើយ។ ដើម្បីឱ្យឧស្សាហកម្មនេះអាចបោះជំហានទៅកាន់កម្រិតខ្ពស់ជាងនេះនៅក្នុងសង្វាក់តម្លៃ គេត្រូវបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយចំណាយធ្វើធុរកិច្ច អភិវឌ្ឍបន្ថែមទៀតនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងថាមពល និងវិនិយោគលើការបណ្តុះបណ្តាលជំនាញ និងសមត្ថភាពរចនាម៉ូដ។

ភាពចាំបាច់មួយទៀត គឺត្រូវបន្តផ្តល់ការលើកទឹកចិត្តជាវិជ្ជមាន ដើម្បីផ្តល់លទ្ធភាពឱ្យរោងចក្រអាចធ្វើការងារឈានទៅកែលំអឧស្សាហកម្មបាន។ អ្នកបញ្ជាទិញគួរផ្តល់រង្វាន់ដល់ការបំពេញការងារប្រកបដោយលក្ខណៈវិជ្ជមានតាមរយៈការបង្កើនការបញ្ជាទិញ ភាពជាប់លាប់នៃការបញ្ជាទិញ និងការបង្កើតនូវទំនាក់ទំនងធុរកិច្ចបែបជាដៃគូរយៈពេលវែង។ លោក វ៉ាន់ ស៊ូអៀង បានលើកឡើងថា ស្ថានភាពបច្ចុប្បន្ននេះមានសារៈសំខាន់ជាពិសេសនៅពេលដែលឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា បានទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារវិបត្តិហិរញ្ញវត្ថុជាសកល។

**សមិទ្ធិផលពាក់ព័ន្ធនឹងសិទ្ធិរបស់កម្មករនិយោជិតត្រូវបានសម្រេច ប៉ុន្តែ ការងារសហជីព និងការចរចាជាសមូហភាព ដើម្បីបង្កើនប្រាក់ឈ្នួល និងលក្ខខណ្ឌការងារនៅតែមានការលំបាក**

លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU) គឺជាអ្នកតំណាងឱ្យសហជីពរបស់ប្រទេសកម្ពុជា។ លោកបានលើកឡើងអំពីទស្សនៈរបស់កម្មករនិយោជិតលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម និងគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* រួមទាំងការវិវឌ្ឍន៍នៃសិទ្ធិកម្មករ ការចងក្រងបង្កើតសហជីព និងការចរចាជាសមូហភាពក្នុងឧស្សាហកម្ម នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ។ លោកបានកត់សម្គាល់ថា ខណៈពេលដែលគោលនយោបាយរបស់រដ្ឋាភិបាលបានបើកឱកាសឱ្យចលនាសហជីពមានការរីកចម្រើន ក៏ចលនាសហជីពនៅតែបន្តជួបប្រទះបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនេះ រួមមានការលំបាកក្នុងការស្នើរឱ្យនិយោជកចូលរួមចរចា បញ្ហានៃការចងក្រងសហជីព និងមានករណីរើសអើងប្រឆាំងអ្នកដឹកនាំសហជីពពីសំណាក់អ្នកគ្រប់គ្រងរោងចក្រ។ ពេលធ្វើការពិភាក្សាអំពីការព្រួយបារម្ភជាក់លាក់ លោក អាត់ ធន់ បានលើកឡើងពីបញ្ហាមួយចំនួនដែលបន្តអូសបន្លាយក្នុងរយៈពេលវែង ដូចជា កិច្ចសន្យារយៈពេលខ្លី ម៉ោងធ្វើការយូរ និងប្រាក់ឈ្នួលអប្បបរមាទាប។

លោក អាត់ ធន់ បានទាញជាសេចក្តីសន្និដ្ឋានថា ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈមទាំងនេះក៏ដោយ ក៏សហជីពនៅក្នុងប្រទេសកម្ពុជាត្រៀមខ្លួនរួចជាស្រេច និងមានឆន្ទៈបន្តធ្វើការងារជាមួយនិយោជក ដើម្បីបង្កើតទំនាក់ទំនងការងារឱ្យល្អប្រសើរ និងបង្កើនផលិតភាព និងសមត្ថភាពប្រកួតប្រជែង។

នៅក្នុងកិច្ចប្រជុំអំពីមេរៀនស្តីពីគោលនយោបាយសាធារណៈ លោកស្រី Sandra Polaski ឧបការីរងរដ្ឋមន្ត្រីក្រសួងការងាររបស់សហរដ្ឋអាមេរិក បានធ្វើការវាយតម្លៃលើការពិសោធន៍លើគោលនយោបាយរបស់ប្រទេសកម្ពុជា ហើយលោក Raymond Robertson សាស្ត្រាចារ្យមហាវិទ្យាល័យ Macalester បានធ្វើបទឧទ្ទេសនាមអំពីការកែលំអការអនុលោមតាមច្បាប់ ហើយលោក John Ritchotte អ្នកឯកទេសផ្នែកកិច្ចសន្ទនាសង្គមរបស់ ILO បានថ្លែងអំពីកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើតទំនាក់ទំនងវិជ្ជាជីវៈល្អ និងបានលើកឡើងអំពីតួនាទីយ៉ាងសំខាន់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពាក់ព័ន្ធនឹងការងារនេះក៏ដូចជាអំពីសមិទ្ធិផលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបាននៅក្នុងការដោះស្រាយវិវាទការងារ និងការបង្កើតនិតិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។

វាគ្មិនមួយរូបទៀតក្នុងសន្និសីទនេះ គឺលោក Michael Kobori អនុប្រធាន Levi Strauss & Co ដែលបានធ្វើបទអន្តរាគមន៍អំពីការបំពេញតម្រូវការរបស់ទីផ្សារ។ នៅក្នុងបទអន្តរាគមន៍របស់ខ្លួន លោក Kobori បានធ្វើការកត់សម្គាល់លើសារៈសំខាន់នៃតម្លាភាពរបស់អ្នកបញ្ជាទិញ និងអ្នកផ្គត់ផ្គង់នៅក្នុងការរាយការណ៍អំពីការអនុលោមតាមច្បាប់។ វាគ្មិនដទៃទៀតរួមមាន លោកស្រី Rachel Kyte អនុប្រធានផ្នែកសេវាប្រឹក្សាធុរកិច្ចរបស់ IFC និងលោកស្រី Jane Steward តំណាងពិសេសរបស់ ILO ប្រចាំអង្គការសហប្រជាជាតិ។ សារៈសំខាន់នៃអភិបាលកិច្ចល្អ ដែលជាកត្តាមួយនៅក្នុងសមត្ថភាពប្រកួតប្រជែង ត្រូវបានលើកឡើងដោយលោក Magdi Amin អ្នកឯកទេសផ្នែកយុទ្ធសាស្ត្ររបស់ IFC ប្រចាំអាស៊ីខាងកើត និងប៉ាស៊ីហ្វិក។

# ខ្ញុំមានតំលៃឆ្នាំ ២០០៩ ឈានមកដល់ទីបញ្ចប់

វគ្គផ្តាច់ព្រ័ត្រនៃការប្រកួតប្រជែង «ខ្ញុំមានតម្លៃ» លើកទីពីរ ដែលជាការប្រកួតប្រជែងរចនាម៉ូដសម្លៀកបំពាក់ និងអាវយឺត ពីសំណាក់កម្មករកម្មការិនីកាត់ដេរ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៩ នៅសាលសន្និសីទចតុមុខ ក្នុងទីក្រុងភ្នំពេញ។



*អ្នកបង្ហាញម៉ូដសម្លៀកបំពាក់ក្នុងវគ្គផ្តាច់ព្រ័ត្រ*

លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានមានប្រសាសន៍ក្នុងពិធីបើកការប្រកួតប្រជែងក្នុងវគ្គផ្តាច់ព្រ័ត្រនេះថា ការប្រកួតប្រជែងនេះរៀបចំឡើងចំពេលដ៏ត្រឹមត្រូវ ដោយសារតែវាចំពេលដែលកំពុងមានវិបត្តិសេដ្ឋកិច្ចកើតមានឡើង ជាពេលដែលចាំបាច់ត្រូវផ្តល់ការទទួលស្គាល់ខ្ពស់បំផុតដល់តួនាទីរបស់ស្ត្រី នៅក្នុងឧស្សាហកម្មកាត់ដេរ។ លោកជំទាវបានបន្ថែមទៀតថា គោលដៅនៃការបង្ហាញឱ្យឃើញពីទេពកោសល្យ និងជំនាញទាំងនេះ គឺជាគោលដៅប្រកបដោយគុណតម្លៃខ្ពស់ ក៏ប៉ុន្តែក៏នៅមានភាពចាំបាច់ជាបន្តទៀត ដើម្បីផ្តល់នូវឱកាសការងារល្អជាងមុនដល់យុវជនមានសមត្ថភាព ដែលកំពុងចូលមកក្នុងទីផ្សារការងារ។

ការប្រកួតប្រជែង «ខ្ញុំមានតំលៃ» ក្រោមប្រធានបទ «ផលិតក្នុងប្រទេសកម្ពុជា» នេះត្រូវបានប្រកាសចាប់ផ្តើមកាលពីពាក់កណ្តាលខែ កក្កដា ឆ្នាំ ២០០៩ និងទុករយៈពេល ២ ខែ សម្រាប់ការដាក់ពាក្យចូលរួមប្រកួត។ ជាលទ្ធផល មានម៉ូដសម្លៀកបំពាក់ និងអាវយឺតជាង ១១០០ ម៉ូដ ត្រូវបានផ្ញើរមកចូលរួមពីកម្មករ_កម្មការិនីចំនួន ៨៦៥ នាក់ ដែលធ្វើការងារនៅក្នុងរោងចក្រកាត់ដេរចំនួន ៣៥។ ការប្រកួតប្រជែងនេះ មានគោលបំណងលើកកម្ពស់គុណតំលៃផ្ទាល់ខ្លួនរបស់កម្មករ_កម្មការិនីកាត់ដេរតាមរយៈការបង្កើនការយល់ដឹងអំពីការងារ សមត្ថភាព និងជំនាញរបស់ពួកគេ និងតាមរយៈការលើកទឹកចិត្តពួកគេឱ្យខិតខំសម្រេចសក្តានុពលភាពរបស់ខ្លួន។

នៅក្នុងការប្រកួតប្រជែងផ្តាច់ព្រ័ត្រនេះ មានការផ្តល់រង្វាន់ដល់អ្នករចនាម៉ូដសម្លៀកបំពាក់ និងអាវយឺតដែលទទួលបានជ័យលាភី ដូចជា ម៉ាស៊ីនដេរ គណនីរីងរួមជាមួយទូរស័ព្ទដៃ និងស៊ីមកាត ទូរទស្សន៍ កង់ និងថវិកាមួយចំនួន។ អ្នកឈ្នះជ័យលាភីក៏ទទួលបានការធានារ៉ាប់រងសុខភាព និងសេវាថែទាំសុខភាពបន្តពូជផងដែរ។ បេក្ខជន បេក្ខនារីដែលជាប់ដល់ជុំចុងក្រោយទាំង ២០ នាក់ បានទទួលអាហារូបករណ៍ចូលរៀនក្នុងវគ្គបណ្តុះបណ្តាលអំពីការផលិតពុម្ពគំរូសម្លៀកបំពាក់នៅមជ្ឈមណ្ឌលឧស្សាហកម្ម ដើម្បីបង្កើនលទ្ធភាពផលិតសម្លៀកបំពាក់ (GIPC)។

យុទ្ធនាការនេះគឺជាការខិតខំប្រឹងប្រែងរួមគ្នាមួយរវាង គំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា* កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP), GIPC, សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងទស្សនាវដ្តីតម្លៃនារី។ យុទ្ធនាការនេះក៏បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហជីព និងអ្នកបញ្ញាទិញអន្តរជាតិផងដែរ។

# និស្សិតមួយក្រុមស្វែងយល់ពីវិស័យកាត់ដេររបស់កម្ពុជា



*និស្សិតមហាវិទ្យាល័យមកពីសហរដ្ឋអាមេរិកធ្វើទស្សនកិច្ចសិក្សាក្នុងរោងចក្រកាត់ដេរមួយ*

ជាផ្នែកមួយនៃដំណើរទស្សនកិច្ចរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា និស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិតចំនួន ១៧ នាក់មកពីមហាវិទ្យាល័យ College of William and Mary នៅសហរដ្ឋអាមេរិកបានធ្វើទស្សនកិច្ចសិក្សាទៅកាន់រោងចក្រមួយ ដែលមានកម្មករ_កម្មការិនីចំនួន ១៣០០ នាក់ កាលពីខែមករា ដើម្បីពិនិត្យមើលដំណើរការផលិតសម្លៀកបំពាក់ និងស្វែងយល់បន្ថែមអំពីឧស្សាហកម្មនេះ។

លោក Steven Yavorsky និស្សិតថ្នាក់ MBA មកពីមហាវិទ្យាល័យ College of William and Mary បានប្តូរទស្សនៈទូទៅរបស់គាត់ដែលយល់ថា ឧស្សាហកម្មនេះធ្វើទង្វើមិនល្អដល់កម្មករ_កម្មការិនី។ លោកបាននិយាយថា «កាលពីមុន ខ្ញុំគ្រាន់តែសន្មត់ថា សម្លៀកបំពាក់ជាច្រើនដែលខ្ញុំទិញយកមកស្លៀកពាក់ ត្រូវបានផលិតឡើងចេញពីលក្ខខណ្ឌការងារដែលមិនល្អខ្លាំង ដោយសារតែអ្វីដែលខ្ញុំបានដឹងឮពីប្រព័ន្ធផ្សព្វផ្សាយ។ ឥឡូវនេះ ខ្ញុំបានដឹងច្រើនជាងមុនអំពីអ្វីដែលប្រទេសកម្ពុជា និងគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*បានធ្វើនៅក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ ខ្ញុំចង់ឃើញពីរបៀបដែលប្រទេសនេះអាចប្រើប្រាស់ឧត្តមភាពប្រកួតប្រជែងនេះបន្ថែមទៀត ដើម្បីបង្កើនការនាំចេញរបស់ខ្លួន»។

លោកបានបន្តទៀតថា «មិនមែនត្រឹមតែគុណភាពនៃសម្លៀកបំពាក់ដែលពួកគេផលិតប៉ុណ្ណោះទេដែលសំខាន់។ លក្ខខណ្ឌការងារដែលប្រកបដោយគុណធម៌ និងមានការទទួលខុសត្រូវចំពោះសង្គមក៏មានសារៈសំខាន់ផងដែរ»។

លោកសាស្ត្រាចារ្យ Don Rahtz ដែលជាអ្នកដឹកនាំក្រុមនិស្សិតនេះ ចាត់ទុកឧស្សាហកម្មកាត់ដេរថា ជាឧស្សាហកម្មដ៏រស់រវើកមួយដែលមានសក្តានុពលយ៉ាងធំធេងក្នុងការបន្តបង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា និងជីវភាពរស់នៅរបស់កម្មករ_កម្មការិនី និងគ្រួសាររបស់ពួកគេ។

លោកបាននិយាយថា «ខ្ញុំគិតថាសមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការធ្វើជាកម្លាំងពលកម្មប្រកបដោយភាពវិជ្ជមាន គឺជាអ្វីដែលប្រទេសអភិវឌ្ឍន៍ដូចជា សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប គួរទទួលស្គាល់ និងផ្តល់ការលើកទឹកចិត្ត»។

លោកបន្ថែមទៀតថា «បើតាមការសង្កេតឃើញរបស់ខ្ញុំ ខណៈពេលដែលប្រទេសកម្ពុជាប្រហែលជាមិនអាចប្រកួតប្រជែងជាមួយប្រទេសចិនផ្នែកតម្លៃ ប្រទេសកម្ពុជាអាចអនុវត្តយុទ្ធសាស្ត្រមួយ ដើម្បីផ្តោតលើទីផ្សារពិសេសៗ និងធ្វើការងារជាមួយអ្នកដែលពិតជាយកចិត្តទុកដាក់ចំពោះបទដ្ឋានការងារនៅក្នុងការផលិត និងការលក់ផលិតផលរបស់ខ្លួន»។

# វិបត្តិសេដ្ឋកិច្ចសកលមាន

## ផលប៉ះពាល់មកលើឧស្សាហកម្មកាត់ដេរ ប៉ុន្តែ ជាទូទៅ លក្ខខណ្ឌការងារនៅតាមរោងចក្រនៅតែមានលក្ខណៈល្អប្រសើរ

ការធ្លាក់ចុះសេដ្ឋកិច្ចសកលលោកក្នុងពេលថ្មីៗនេះ មានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

បើតាមរបាយការណ៍សំយោគទី ២៣ ដែលចេញដោយគំរោង *រោងចក្រកាន់តែប្រសើរនៅកម្ពុជា*នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ បានឱ្យដឹងថា លក្ខខណ្ឌការងារនៅតាមរោងចក្រនានា ជាទូទៅ នៅតែមានភាពល្អប្រសើរ បើទោះបីជារោងចក្រកាន់តែទទួលរងសម្ពាធខ្លាំងឡើងៗ ដោយសារតែវិបត្តិសេដ្ឋកិច្ចនេះក៏ដោយ។ សម្រាប់ព័ត៌មានពិស្តារនៃរបាយការណ៍នេះសូមចូលទៅកាន់គេហទំព័រ http://www.betterfactories.org/ILO/resources.aspx?z=7&c=1.



# ជ័យលាភីនៃការប្រកួតប្រជែង "ខ្ញុំមានតំលៃ" ឆ្នាំ ២០០៩



*កញ្ញា ឃាន វ៉ាន់ថា (ខាងស្តាំ) និងអ្នកបង្ហាញម៉ូដរបស់នាង*

### កញ្ញា ឃាន វ៉ាន់ថា ជ័យលាភីលេខមួយផ្នែករចនាម៉ូដសម្លៀកបំពាក់

កញ្ញា ឃាន វ៉ាន់ថា អាយុ ៣០ ឆ្នាំ បានឈ្នះការប្រកួតប្រជែងវិញ្ញាសាររចនាម៉ូដសម្លៀកបំពាក់ជាមួយនឹងរ៉ូបរាត្រីពណ៌ខៀវអមជាមួយក្រណាត់ក្រវ៉ាត់ពណ៌ស្វាយ និងខៀវខ្ចី ដែលកញ្ញាដាក់ឈ្មោះថា «ម៉ូដកន្ទុយត្រី»។

បំណងប្រាថ្នាក្នុងការរចនាម៉ូដសម្លៀកបំពាក់ ដែលបានឈ្នះជ័យលាភីនេះ កើតចេញពីការមើលម៉ូដសម្លៀកបំពាក់ផ្សេងៗតាមកញ្ចក់ទូរទស្សន៍ដែលធ្វើឱ្យនាងចង់ធ្វើអ្វីដែលលេចធ្លោដោយខ្លួនឯង។ នៅពេលដែលនាងឃើញម៉ូដសម្លៀកបំពាក់របស់ខ្លួននៅលើឆាក នាងគិតថា ម៉ូដនេះជាម៉ូដប្លែក និងអាចជាម៉ូដដែលល្អលើសគេ។

វ៉ាន់ថា មកពីខេត្តកំពង់ចាម ហើយបាននឹងកំពុងធ្វើការងារក្នុងរោងចក្រសេនចូវរយៈពេលជិត ៤ ឆ្នាំហើយ។

វ៉ាន់ថា រចនាម៉ូដសម្លៀកបំពាក់គ្រប់ពេលទាំងអស់។ នាងរចនាម៉ូដសម្លៀកបំពាក់សម្រាប់ញាតិមិត្តរបស់ខ្លួន និងសម្រាប់ខ្លួនឯងសម្រាប់ស្លៀកក្នុងឱកាសផ្សេងៗ។ នាងជឿថា អ្នករចនាម៉ូដដែលពូកែត្រូវដឹងអំពីប្រភេទម៉ូដដែលស័ក្តិសមនឹងមនុស្សម្នាក់ និងរបៀបដាក់ពណ៌ និងក្រណាត់ផ្សេងៗគ្នាបញ្ចូលគ្នា។

ចាប់តាំងពីមានព្រឹត្តិការណ៍នេះមក មិត្តភ័ក្ត្រ និងមិត្តរួមការងារក្នុងរោងចក្ររបស់នាងជាច្រើនផ្តល់ការកោតសរសើរដល់នាង ហើយបានលើកទឹកចិត្តឱ្យនាងបន្តការងាររចនាម៉ូដសម្លៀកបំពាក់នេះទៀត។ នាងមានការសប្បាយរីករាយជាពិសេស ដែលបានទទួលអាហារូបករណ៍ចូលរៀនក្នុងវគ្គផលិតពុម្ពគំរូសម្លៀកបំពាក់ ដោយនាងសង្ឃឹមថាវគ្គបណ្តុះបណ្តាលនេះអាចនាំឱ្យនាងឈានជើងមួយជំហានទៀត ដើម្បីសម្រេចសុបិន្តរបស់នាងដែលចង់ក្លាយជាអ្នករចនាម៉ូដសម្លៀកបំពាក់អាជីពដែលល្បីឈ្មោះនៅក្នុងប្រទេសកម្ពុជា។

### កញ្ញា ប៉េះ សំបូរ ជ័យលាភីលេខមួយផ្នែករចនាម៉ូដអាវយឺត



*កញ្ញា ប៉េះ សំបូរ (ខាងស្តាំ) និងអ្នកបង្ហាញម៉ូដរបស់នាង*

កញ្ញា ប៉េះ សំបូរ អាយុ ២៤ ឆ្នាំ ក៏ធ្វើការងារនៅក្នុងរោងចក្រសេនចូវផងដែរ។ នាងរចនាម៉ូដអាវយឺតដ៏ស្រស់ស្អាតមួយ លំអដោយផ្កា និងមេអំបៅ ដែលជាម៉ូដឈ្នះការប្រកួតប្រជែងផ្នែកអាវយឺត។

សំបូរ មានស្រុកកំណើត នៅក្នុងខេត្តស្វាយរៀង។ នៅពេលដែលនាងចូលរួមនៅក្នុងការប្រកួតប្រជែងនេះ នាងមិនគិតថា ការប្រកួតប្រជែងនេះធំដូច្នេះឡើយ។ ប៉ុន្តែ ឥឡូវនេះ នាងមានអារម្មណ៍ថា យុទ្ធនាការទាំងមូលនេះបានផ្តល់ឱ្យនាងនូវបទពិសោធន៍ ជំនាញ និងមិត្តភ័ក្ត្រជិតស្និទ្ធថ្មីៗន្ថែមទៀត។

សម្បូរបាននិយាយថា «តាំងពីពេលចាប់ផ្តើម រហូតដល់ចុងបញ្ចប់ ខ្ញុំរៀនចេះច្រើនអំពីម៉ូដសម្លៀកបំពាក់។ ឥឡូវនេះ ខ្ញុំក៏យល់ផងដែរថាកម្មករ_កម្មការិនីគឺជាមនុស្សមានតម្លៃ បើទោះបីជាមិនមែនកម្មករ_កម្មការិនីគ្រប់រូបសុទ្ធតែមានឱកាសបង្ហាញពីសមត្ថភាពរបស់ពួកគេក៏ដោយ»។

នៅក្នុងព្រឹត្តិការណ៍នេះដែរ សំបូរមានអារម្មណ៍រីករាយ ដោយសារតែនាងមានកិត្តិយសអង្គុយលើវេទិកាកិត្តិយសពីមុខភ្ញៀវសំខាន់ៗដែលក្នុងនោះមានរដ្ឋមន្ត្រី ក្រសួងកិច្ចការនារីផងដែរ។ នាងនិយាយថា «ប៉ុន្តែ ខ្ញុំក៏ហាក់ដូចជាភ័យបន្តិចផងដែរ។ នៅពេលដែលគេប្រកាសឈ្មោះខ្ញុំ ខ្ញុំរំភើបយ៉ាងខ្លាំង ហើយខ្ញុំចង់ស្រែក ប៉ុន្តែ ខ្ញុំមិនហ៊ាន។ ខ្ញុំមិនដែលរំពឹងថាអាចក្លាយជាអ្នកឈ្នះជ័យលាភីដូច្នេះឡើយ បើទោះបីជាខ្ញុំគិតថាម៉ូដអាវយឺតរបស់ខ្ញុំស្អាតក៏ដោយ»។

បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលឧស្សាហកម្មដើម្បីបង្កើនលទ្ធភាពផលិតសម្លៀកបំពាក់ (GIPC) រួចសំបូរចង់យកប្រាក់ដែលនាងឈ្នះពីការប្រកួតប្រជែងនេះទៅ វិនិយោគលើវគ្គបណ្តុះបណ្តាលមួយផ្សេងទៀតសម្រាប់ឱ្យនាងអាចបង្កើនជំនាញរបស់ខ្លួន ដើម្បីធ្វើឱ្យសុបិន្តចង់បើកហាងកាត់ដេរដោយខ្លួនឯងរបស់នាងក្លាយជាការពិត។

# មជ្ឈមណ្ឌលការងារត្រូវបានប្រកាស ចាប់ផ្តើមដំណើរការ ដើម្បីលើកកម្ពស់ការងារ និងជំនាញ



*កម្មករនិយោជិតបាត់បង់ការងារ (ខាងស្តាំ) កំពុងសួរព័ត៌មានអំពីការងារ*

ឥឡូវនេះ មជ្ឈមណ្ឌលការងារ ចំនួន ២ ដំបូងបង្អស់ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមដំណើរការហើយ។ អង្គការពលកម្មអន្តរជាតិ (ILO) បានផ្តល់ការគាំទ្រដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតមជ្ឈមណ្ឌលការងារទាំងនេះ ក្នុងគោលបំណងបញ្ជូនកម្មករនិយោជិតគ្មានការងារធ្វើទៅកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងជួយដល់កម្មករនិយោជិតគ្មានការងារធ្វើដែលកំពុងស្វែងរកព័ត៌មានអំពីការងារ។

មជ្ឈមណ្ឌលការងារទាំងពីរមានទីតាំងក្នុងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសក្នុងទីក្រុងភ្នំពេញ និងវិទ្យាស្ថានពហុបច្ចេកទេសក្នុងខេត្តបាត់ដំបង។

មជ្ឈមណ្ឌលការងារ គឺជាផ្នែកមួយនៃការឆ្លើយតបជាបន្ទាន់ចំពោះវិបត្តិសេដ្ឋកិច្ច និងជាកិច្ចខិតខំប្រឹងប្រែងរយៈពេលវែង ដើម្បីពង្រឹងសេវាការងារ និងការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញទៅតាមតម្រូវការទីផ្សារនៅក្នុងប្រទេស។

មជ្ឈមណ្ឌលការងារទាំងនេះនឹងផ្តល់សេវាទីផ្សារការងារ ក៏ដូចជាប្រមូល និងផ្សព្វផ្សាយព័ត៌មានអំពីទីផ្សារការងារនៅក្នុងមូលដ្ឋាន។ មជ្ឈមណ្ឌលទាំងនេះក៏នឹងផ្តល់ទិន្នន័យសំខាន់ៗដល់អ្នកតាក់តែងគោលនយោបាយរបស់ទីភ្នាក់ងារជាតិនៃមុខរបរ ដែលនឹងបង្កើតឡើងនៅក្នុងឆ្នាំ ២០១០ ផងដែរ ហើយនឹងភ្ជាប់ទំនាក់ទំនងរវាងអតិថិជន ជាមួយនឹងអ្នកផ្តល់សេវាបណ្តុះបណ្តាល និយោជក និងសេវាគាំទ្រអាជីវកម្មផ្សេងៗ។ មជ្ឈមណ្ឌលទាំងនេះក៏នឹងជួយផ្តល់ការណែនាំ និងផ្តល់ប្រឹក្សាអំពីអាជីពការងារ និងបញ្ជូនអ្នកស្វែងរកការងារទៅកាន់កម្មវិធីបណ្តុះបណ្តាល ឬកម្មវិធីបណ្តុះបណ្តាលឡើងវិញ ដើម្បីអាចរកការងារបានធ្វើ។

នៅក្នុងឆ្នាំ ២០១០ មជ្ឈមណ្ឌលការងារ ចំនួន ២ កន្លែងទៀតនឹងត្រូវបង្កើតឡើងនៅក្នុងខេត្តកំពត និងខេត្តសៀមរាប។ មជ្ឈមណ្ឌលការងារទាំងនេះបើកទ្វារ ៨ ម៉ោងក្នុងមួយថ្ងៃ ពីពេលព្រឹក រហូតដល់រសៀល និង ៥ ថ្ងៃក្នុងមួយសប្តាហ៍ ដកថ្ងៃចុងសប្តាហ៍ចេញ។ ទាំងកម្មករនិយោជិត ទាំងនិយោជក ត្រូវបានលើកទឹកចិត្តឱ្យមកចុះឈ្មោះ និងប្រើប្រាស់សេវារបស់មជ្ឈមណ្ឌលការងារទាំងនេះ ដោយមិនគិតថ្លៃអ្វីទាំងអស់។

**ទីតាំងរបស់មជ្ឈមណ្ឌលការងារ:**

*ទីក្រុងភ្នំពេញ*
វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស សង្កាត់ទឹកថ្លា
ខណ្ឌសែនសុខ ទីក្រុងភ្នំពេញ
លេខទូរស័ព្ទ: ០៩៨ ៧១៧ ៩២០ ឬ ០១២ ៩០០ ៩៥១
វិបសាយ: http://www.ntti.edu.kh

*ខេត្តបាត់ដំបង*
វិទ្យាស្ថានពហុបច្ចេកទេសបាត់ដំបង ភូមិព្រៃកមហាទេព
សង្កាត់ស្វាយប៉ោ ខេត្តបាត់ដំបង
លេខទូរស័ព្ទ: ០៥៣ ៩៥៣ ៥៨០ ឬ ០៩២ ៤៥០ ៤០៥
អ៊ីមេល: btb_jobcenter@yahoo.com

# លេខទូរស័ព្ទទំនាក់ទំនង បន្ទាន់សម្រាប់ករណីវិបត្តិសេដ្ឋកិច្ច




គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា*កំពុងធ្វើការងារក្នុងភាពជាដៃគូជាមួយគម្រោងអន្តរភាគីប្រឆាំងការជួញដូរមនុស្សរបស់សហប្រជាជាតិ (UNIAP) ស្ថាប័នមីក្រូហិរញ្ញវត្ថុអង្គរ (AMK) សម្ព័ន្ធចាប់ដៃ និងអង្គការទស្សនៈពិភពលោក ដើម្បីបង្កើនការយល់ដឹងអំពីប្រភពជំនួយសម្រាប់កម្មករនិយោជិតក្នុងកំឡុងពេលមានវិបត្តិសេដ្ឋកិច្ចជាសកលនេះ។ លេខទូរស័ព្ទទំនាក់ទំនងនេះគឺ **០១១ ៥២៥ ៥៥១** ហើយវាជាផ្នែកមួយនៃការងារ ដើម្បីឆ្លើយតបចំពោះវិបត្តិនេះ។

# ការប្រកួតប្រជែងចំណេះដឹង អំពីច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា



ដោយសហការជាមួយវិទ្យុមហានគរ អេហ្វអឹម ៩៣,៥ គំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* បានផ្តួចផ្តើមឱ្យមានការប្រកួតប្រជែងមួយ សម្រាប់កម្មករនិយោជិតកាត់ដេរលើចំណេះដឹងស្តីពីច្បាប់ការងាររបស់ប្រទេសកម្ពុជា។

កម្មវិធីនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងអំពីច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារដល់កម្មករនិយោជិត និងសាធារណៈជនទូទៅ ក៏ដូចជាដើម្បីលើកកម្ពស់ឧស្សាហកម្មកាត់ដេរទាំងមូល។

នៅក្នុងការប្រកួតប្រជែងនេះ អ្នកឈានដល់ជុំចុងក្រោយចំនួន ១២ នាក់ នឹងប្រកួតប្រជែងជាមួយគ្នា ក្នុងការផ្សាយផ្ទាល់តាមវិទ្យុរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ រសៀល ដល់ម៉ោង ៤ រសៀល ចាប់ពីថ្ងៃទី ៦ ខែ មីនា រហូតដល់ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១០។

# ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យ ការងារ: ផលប៉ះពាល់វិជ្ជមានមកលើលក្ខខណ្ឌការងារ និងផលិតភាព

ការវិនិយោគលើការអភិវឌ្ឍន៍ជំនាញមានសារៈសំខាន់ដើម្បីរក្សា និងពង្រឹងភាពរស់រវើកនៃឧស្សាហកម្មកាត់ដេរកម្ពុជា។ ការសិក្សាមួយដែលបានធ្វើឡើងដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ideas42 (សកលវិទ្យាល័យ Harward) និងដែលបានចេញផ្សាយកាលពីខែ វិច្ឆិកា ឆ្នាំ ២០០៩ បានផ្តល់នូវភ័ស្តុតាងបែបវិទ្យាសាស្ត្រអំពីផលប៉ះពាល់វិជ្ជមាននៃការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារទៅលើលក្ខខណ្ឌការងារផង និងលើផលិតភាពផង[1]។

ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារ ដែលបានអនុវត្តដោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ដោយមានការគាំទ្រពី Business Dynamics Cambodia មានគោលបំណងផ្តល់ការបណ្តុះបណ្តាលដល់មេការផ្ទាល់ និងមេការប្រយោលនៅក្នុងរោងចក្រកាត់ដេរកម្ពុជា[2]។ គោលដៅនៃការបណ្តុះបណ្តាលនេះ គឺដើម្បីផ្តល់ឱ្យមេការទាំងនោះនូវចំណេះដឹងជំនាញត្រួតពិនិត្យការងារ និងឥរិយាបថវិជ្ជមាន ដើម្បីកែលំអទំនាក់ទំនងការងាររវាងកម្មករនិយោជិត និង មេការ និងដើម្បីបង្កើនផលិតភាព។ កម្មវិធីបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារនេះមានរយៈពេល៤ថ្ងៃ ហើយក្នុងមួយថ្ងៃមានរយៈពេល ៦ម៉ោង ដែលបង្រៀនដោយគ្រូបណ្តុះបណ្តាលដែលមានជាភាសាខ្មែរ និងភាសាចិន។ រហូតមកដល់បច្ចុប្បន្ននេះ កម្មវិធីនេះបានផ្តល់ការបណ្តុះបណ្តាលដល់មេការប្រហែលជា ១៥០០ នាក់ ដែលភាគច្រើនជាស្ត្រីនៅក្នុងរោងចក្រចំនួន ៦៣។

ផ្អែកទៅតាមការស្ទាបស្ទង់មតិ ដែលធ្វើឡើងដោយចោះៗលើមេការចំនួន ១៧៣ នាក់ និងកម្មករនិយោជិតក្រោមការគ្រប់គ្រងរបស់ពួកគេ (និងក្រុមត្រួតពិនិត្យ) អ្នកស្រាវជ្រាវបានរកឃើញភ័ស្តុតាងបង្ហាញពីផលប៉ះពាល់វិជ្ជមាន និងគួរឱ្យកត់សម្គាល់នៃការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារទៅលើការពេញចិត្តនឹងការងាររបស់កម្មករនិយោជិត។ ក្នុងចំណោមកម្មករនិយោជិត ស្ថិតក្រោមការគ្រប់គ្រងរបស់មេការផ្ទាល់ ដែលបានទទួលការបណ្តុះបណ្តាល ២០% បង្ហាញថា ទំនាក់ទំនងរវាងពួកគេជាមួយនឹងមេការរបស់ពួកគេមានភាពល្អប្រសើរ ក្រោយការបណ្តុះបណ្តាល។ ស្រដៀងគ្នានេះដែរ លទ្ធផលបង្ហាញថា កម្មករនិយោជិតមានការយល់ដឹងច្រើនជាងមុនចំនួន ២៥% អំពីគោលដៅផលិតកម្ម និង ១០% បានទទួលការណែនាំ និងមតិកែលំអបានញឹកញាប់ជាងមុន។

ផលប៉ះពាល់វិជ្ជមាននៃការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារទៅលើទំនាក់ទំនងរវាងមេការ និងកម្មករនិយោជិត គឺកាន់តែគួរឱ្យកត់សម្គាល់បន្ថែមទៀតនៅក្នុងករណីដែលទាំងមេការផ្ទាល់ និងមេការប្រយោលបានទទួលការបណ្តុះបណ្តាល។

ពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់នៃការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារទៅលើផលិតកម្មវិញ ការវិភាគលើឯកសាររបស់រោងចក្របានបង្ហាញថា ការបណ្តុះបណ្តាលមេការប្រយោលធ្វើឱ្យទិន្នផលការងារកើនឡើងចំនួន ១០%។ ជាមធ្យមកម្មករនិយោជិតបានរាយការណ៍ពីការធ្វើការបន្ថែមម៉ោងតិចជាងមួយម៉ោងក្នុងមួយថ្ងៃ។ ពួកគេក៏បានរាយការណ៍ពីការធ្វើការបន្ថែមម៉ោងតិចជាងមួយថ្ងៃក្នុងមួយសប្តាហ៍ផងដែរ។ យោងទៅតាមការសិក្សានេះផលប៉ះពាល់នេះមានទំហំតូចក្រោយការបណ្តុះបណ្តាលភ្លាមៗ (នៅក្នុងរយៈពេល ២ ខែដំបូង) ប៉ុន្តែកាន់តែមានទំហំធំឡើងៗគិតចាប់ពីខែទី ៣ ឡើងទៅ។

ដើម្បីកែលំអផ្នែក «ទន់» នៃបរិយាកាសការងារ (ដូចជា ការពេញចិត្តនឹងការងារ និងការគ្រប់គ្រងប្រចាំថ្ងៃ) ការបណ្តុះបណ្តាលមេការផ្ទាល់មានសារៈសំខាន់ជាង។ ផ្ទុយទៅវិញ ចំពោះផ្នែក«រឹង» ដូចជា ការកែលំអពេលវេលាផលិតកម្ម និងការប្រាស្រ័យទាក់ទងអំពីពេលវេលាកំណត់និងគោលដៅទិន្នផលការងារវិញ ការបណ្តុះបណ្តាលមេការប្រយោលមានសារៈសំខាន់ជាង។



*កញ្ញា Liu Chun Ying (រូបកណ្តាល) ជាអ្នកគ្រប់គ្រងផ្នែកត្រួតពិនិត្យគុណភាពនៅក្នុងរោងចក្រកាត់ដេរមួយ ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីការត្រួតពិនិត្យការងារកំពុងបង្ហាត់បង្រៀនដល់បុគ្គលិករបស់គាត់*

លទ្ធផលនៃការសិក្សានេះផ្តល់ការគាំទ្រឱ្យមានករណីអាជីវកម្ម សម្រាប់កែលំអលក្ខខណ្ឌការងារ ដែលមានទំនាក់ទំនងជាមួយនឹងកម្មករនិយោជិតដែលទទួលបានការបណ្តុះបណ្តាលប្រសើរជាងមុន៖ នៅក្នុងករណីបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារ ការពេញចិត្តនឹងការងាររបស់កម្មករនិយោជិត និងផលិតភាពមិនមែនជាគោលដៅប្រជែងគ្នានោះទេ ប៉ុន្តែជាគោលដៅដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។

---

[1] IFC (២០០៩) *«ការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យការងារនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា: ការវាយតម្លៃលើ ផលប៉ះពាល់ដោយចោះៗ»* ។ *http://www.betterwork.org/public/global/public-files/publications/supervisory-skills-training-in-the-cambodian-garment-industry-a-randomized-impact-evaluation/view* ។

[2] *មេការផ្ទាល់ ត្រួតពិនិត្យកម្មករនិយោជិតក្នុងខ្សែផលិតកម្ម ចំណែកឯមេការប្រយោល ត្រួតពិនិត្យការងាររបស់ប្រធានក្រុម។*


ព្រឹត្តិប័ត្រនេះ ត្រូវបានបោះពុម្ពផ្សាយដោយគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ ។
ទស្សនៈទាំងឡាយនៅក្នុងព្រឹត្តិប័ត្រនេះ មិនជាចាំបាច់ឆ្លុះបញ្ចាំងពីទស្សនៈជាផ្លូវការរបស់អង្គការពលកម្មអន្តរជាតិឡើយ ។
ផ្ទះលេខ ៩ ផ្លូវលេខ ៣២២ សង្កាត់បឹងកេងកងទី ១ ភ្នំពេញ កម្ពុជា – ប្រអប់សំបុត្រលេខ ២៦៤២
ទូរស័ព្ទ: (៨៥៥–២៣) ២១២ ៨៤៧ លេខបន្ត ១០៦ – ទូរសារ: (៨៥៥–២៣) ២១២ ៩០៣
សម្រាប់ការទទួលយកព្រឹត្តិប័ត្រអេឡិចត្រូនិច សូមចុះឈ្មោះតាមរយៈវិបសាយ www.betterfactories.org/ilo
សម្រាប់ចម្ងល់ផ្សេងៗ សូមទាក់ទងមកកាន់មន្ត្រីទំនាក់ទំនង តាមរយៈអ៊ីម៉េល betterfactories@ilo.org